**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2014, 13:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារដែលបានស្នើឡើងដោយ កសព ដូចមានឈ្មោះក្នុងបញ្ជីនៃឧបសម្ព័ន្ធ គ២ និង ឃ៣ នៅក្នុងសំណុំរឿង និងដាក់លេខឯកសារទាំងនោះ**

__អ្នកដាក់ឯកសារ:__
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

__អ្នកទទួលឯកសារ:__
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តរា

__ចម្លងជូន:__
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្តីជនជាប់ចោទ**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

## សេចក្តីសន្និដ្ឋាន

១. ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E305[1] តាមរយៈការដាក់បញ្ជីឯកសារសម្រាប់សំណុំរឿង០០២/០២របស់ខ្លួន អនុលោមតាមវិធាន៨០(៣) ដែលមានឧបសម្ព័ន្ធសម្ងាត់ចំនួន ២៣[2]។ **ឧបសម្ព័ន្ធសម្ងាត់ គ២** មានឯកសារចំនួន៤៧៣ ដែលមិនទាន់បានដាក់នៅឡើយពីមុនមក ហើយដែលសហព្រះរាជអាជ្ញាបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២។ ដោយសារតែឯកសារទាំងនោះ មិនទាន់បានបញ្ចូលទៅក្នុងសំណុំរឿង ឯកសារទាំងនេះត្រូវបាន កសព ដាក់ជាបណ្តោះអាសន្ននៅលើឃ្លាំងផ្ទុកឯកសាររួម ដើម្បីឲ្យភាគី និងអង្គជំនុំជម្រះបានពិនិត្យមើលឡើងវិញ[3]។

២. នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារបន្ថែមមួយសម្រាប់សវនាការ អនុលោមតាមវិធាន៨០(៣) ដោយមានឧបសម្ព័ន្ធសម្ងាត់ចំនួនបីភ្ជាប់ទៅជាមួយ ដែលបង្កើតបានជាចម្លើយតបបន្ថែមមួយទៀត ទៅនឹងដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E305[4]។ **ឧបសម្ព័ន្ធសម្ងាត់ ឃ៣** បានបន្ថែម **ឧបសម្ព័ន្ធ គ២** ហើយមានឯកសារពាក់ព័ន្ធចំនួន២៦ ដែលមិនមាននៅក្នុងសំណុំរឿង០០២ ដែលសហព្រះរាជអាជ្ញាបានស្នើឲ្យទទួលយក។ ដូចបានអនុវត្តពីមុនមកសម្រាប់ឯកសារដែលបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ គ២**, ឯកសារ **ឧបសម្ព័ន្ធ ឃ៣** ត្រូវបានដាក់ជាបណ្តោះអាសន្នដោយ កសព នៅលើឃ្លាំងផ្ទុកឯកសាររួម ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចសម្រេចដាក់ឯកសារទាំងនោះចូលក្នុងសំណុំរឿង។

៣. នៅក្នុង "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសំណើរួមស្នើសុំឲ្យសម្រេចឡើងវិញស្តីពីការអនុវត្តវិធាន៨៧(៤)នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤" អង្គជំនុំជម្រះសាលា

---

[1] **E305** ដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ឲ្យដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការក្នុងសំណុំរឿង០០២/០២, ៨ មេសា ២០១៤។

[2] **E305/13** បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣) នៃវិធានផ្ទៃក្នុង, ១៣ មិថុនា ២០១៤។

[3] **E305/13** បញ្ជីឯកសារសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣) នៃវិធានផ្ទៃក្នុង, ១៣ មិថុនា ២០១៤, កថាខណ្ឌ៥។

[4] **E305/13/1** បញ្ជីឯកសារបន្ថែមសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០(៣) នៃវិធានផ្ទៃក្នុង, ៥ កញ្ញា ២០១៤ និងឧបសម្ព័ន្ធសម្ងាត់៣ E305/13/1.1 ដល់ 3។

ដំបូងបានសម្រេចថា បញ្ជីឯកសារសវនាការឆ្នាំ២០១៤របស់ភាគី ត្រូវបានពិចារណាថា "ជាសំណៅបញ្ជីឆ្នាំ២០១១ ដែលបានកែសម្រួល ដែលពុំចាំបាច់អនុវត្តតាមលក្ខខណ្ឌនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ" និងថា មានតែសំណើ *"ទាពេលខាងមុខ"* សុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារថ្មី ឬស្តាប់សាក្សីថ្មីតែប៉ុណ្ណោះ ដែលត្រូវស្ថិតក្រោមលក្ខខណ្ឌនៃវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង"[5]។

៤. តាមស្មារតីនៃសេចក្តីសម្រេចនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

(១) បញ្ជូនឯកសារចំនួន៤៩៩ ដែលបានចុះបញ្ជីក្នុង **ឧបសម្ព័ន្ធ គ២** និង **ឃ៣** ដូចបានយោងខាងលើ ពីសំណុំឯកសារពិសេសរបស់ កសព នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ទៅក្នុងសំណុំរឿង។

(២) ដាក់ឯកសារដែលបានបញ្ជូនទាំងនេះទៅជាលេខឯកសារក្នុងសំណុំរឿង (មានន័យថា លេខ E) ដើម្បីជួយសម្រួលដល់ការលើកយោងដោយគូភាគី និងអង្គជំនុំជម្រះ ក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធី (ឧ. សម្រាប់សំណើសុំ ឬការទទួលយក និងសវនាការលើអង្គសេចក្តី) ហើយ;

(៣) ធ្វើឲ្យឯកសារអាចរកបាននៅលើ Zylab ដើម្បីឲ្យភាគីអាចដាក់ឯកសារទាំងនេះ នៅលើអ៊ីនធឺណេតប្រចាំថ្ងៃ (Interface) នៅមុនពេលសវនាការលើអង្គសេចក្តី៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |

[5] **E307/1/2** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណើសុំរួមឲ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង, ២១ តុលា ២០១៤, កថាខណ្ឌ១១ & ១២។